★ ការតវ៉ាជាមួយរដ្ឋាភិបាល និង ជួយគាំទ្រចំពោះបញ្ហាជនភៀសខ្លួន។

★ ការសិក្សាស្រាវជ្រាវ។

**ការបញ្ជូនមកកាន់ក្រសួង**

យើងទទួលយកការបញ្ជូនមកពីគ្រប់មជ្ឈដ្ឋាន រួមបញ្ចូលការបញ្ជូនដោយខ្លួនឯងនៅក្នុងលក្ខណៈម្នាក់ៗ ឬ ជាគ្រួសារ ដែលមានបញ្ហាទាក់ទងទៅនិងការជួបប្រទះការភ័យតក់ស្លុត សូមទូរស័ព្ទទាក់ទងជាមួយ ភ្នាក់ងារទទួលការបញ្ជូន តាមលេខ ០២-៩៧៩៤ ១៩០០។

STARTTS បានរៀបចាត់ចែងតារាងវេនចាំដោយផ្អែកទៅលើការពិនិត្យនូវអាទិភាពនៃសេចក្តីត្រូវការរបស់អតិថិជនម្នាក់ៗ។

សព្វថ្ងៃយើងមាន អ្នកពិភាក្សានិងបួរយោបល់ដែលនិយាយភាសាដូចតទៅនេះ៖ Arabic,Bosnia, Croatioan,Dari, Farsi ,French Hindi, **Khmer ( ខ្មែរ )**, Pashtu, Portuguese, Serbian, Spenish, Tetum, Urdu and Vietnamese។

បើសិនអតិថិជនណានិយាយភាសាផ្សេងពីនេះ យើងអាចរៀបចំអ្នកជំនាញបកប្រែភាសារជូន។

" កិច្ចបំរើនៅ STARTTS ផ្តល់ជូនដោយឥតបង់ថ្លៃ "

" STARTTS មិនមែនមន្ទីរព្យាបាលជនវិកលចរិតទេ "

**មធ្យោបាយដើម្បីមកកាន់ STARTTS**

**ទិសដំណើរចេញមកពី Fairfield**




**អាស័យដ្ឋានលេខ 152 - 168 The Horsley Drive**
**CARRAMAR, NSW.**

**Bus លេខ៨១៧ ចេញពី Cabramatta មកកាន់ Fairfield**
**Bus លេខ៨១៨ ចេញពី Fairfield ទៅកាន់**
**Chester Hill**

**ពត៌មានបន្ថែមអំពី STARTTS សូមមេត្តា**
**ទាក់ទងមកយើងតាមរយៈ**
**ទូរស័ព្ទ: ០២ – ៩៧៩៤ ១៩០០**
**ទូរលេខ: ០២ – ៩៧៩៤ ១៩១០**

**ការិយាល័យបើកទ្វារពីម៉ោង ៨:៣០ព្រឹក-៥:០០រសៀល**
**ថ្ងៃច័ន្ទ ទៅដល់ ថ្ងៃសុក្រ។**

**កិច្ចបំរើសំរាប់ការព្យាបាល និង ទ្រទ្រង់ឲ្យបានល្អឡើងវិញចំពោះអ្នកនៅរស់ពីទារុណកម្ម និងការភ័យតក់ស្លុត**

*SERVICE FOR THE TREATMENT AND REHABILITATION OF TORTURE AND TRAUMA SURVIVORS, NSW.*

# *S.T.A.R.T.T.S.*

" កិច្ចបំរើរបស់យើងធ្វើតាមក្រិត្យក្រមយ៉ាងតឹងរឹងបំផុតចំពោះការលាក់ការសម្ងាត់ និង ភាពមិនលំអៀង "

Khmer

**មូលហេតុដែលបង្កើតក្រសួង** STARTTS

ប្រទេសអូស្ត្រាលីបានផ្តល់ជំរកចំពោះជនភៀសខ្លួនមកពីប្រទេសដែលមានសញ្ជាតិ វប្បធម៌ សាសនា និង ភាសាផ្សេងៗគ្នាជាច្រើន នៅជុំវិញពិភពលោកចាប់តាំងពីពេលបញ្ចប់សង្គ្រាមលោកលើកទី២មក។
យោងតាមកិច្ចព្រមព្រៀងនោះសព្វថ្ងៃនេះមានប្រជាជនថ្មីចំនួន ១០,០០០នាក់ក្នុងមួយឆ្នាំមកនៅក្នុងប្រទេសអូស្ត្រាលីដែលមានប្រមាណជាង ៤០% នៃអ្នកទាំងនោះបានមកតាំងទីលំនៅថ្មីនៅក្នុងរដ្ឋ NSW ហើយប្រមាណជាង ៦០% នៃអ្នកទាំងនេះត្រូវបានប៉ាន់ស្មានថាជាអ្នកដែលនៅរស់ពីទារុណកម្ម ឬ ភ័យតក់ស្លុត។

ផលវិបាកខាងផ្លូវកាយដែលបានទទួលពីទារុណកម្មអាចរាប់បញ្ចូល៖ការឈឺចាប់រាំរ៉ៃ, បាក់ឆ្អឹង, បាក់ធ្មេញ, ខូចភ្នែក, ត្រចៀក, ប្រដាប់ភេទ, សរីរាងបន្តពូជ, ខួរក្បាលការប្រែប្រួលរបស់បេះដូង-សួត និង ជម្ងឺផ្សេងៗ ដែលជាលទ្ធផលវិបាកមកពីលក្ខណៈភាពនៃការជាប់ឃុំឃាំង។

ប៉ុន្តែជារឿយៗ ភាគច្រើនការរងគ្រោះខាងផ្លូវចិត្តបង្កើតឲ្យមានភាពទុក្ខព្រួយ និង ទន់ខ្សោយ។ បញ្ហាទាំងនោះអាចរាប់បញ្ចូល៖ ការពិបាកចិត្ត, ការព្រួយបារម្ភយ៉ាងខ្លាំង, ការប្រែប្រួលដំណេក (ជាពិសេសសុបិន្តអាក្រក់) រស់នៅទាំងសោកសៅ, បាត់បង់កំលាំងទឹកចិត្ត, មានបញ្ហាខាងការចងចាំ និងផ្លង់ស្មារតី, ការជ្រៀតជ្រែកក្នុងគំនិត និង ការនឹកឃើញរឿងអតីតកាលជារឿយៗ, ពិបាកចូលរួមសកម្មភាពក្នុងសង្គមហើយនិង ទំនាស់នៅក្នុងគ្រួសារ។

បន្ថែមពីលើបញ្ហាទាំងនេះជនភៀសខ្លួនជួបប្រទះនូវការបាត់បង់ជាច្រើន និង សេចក្តីត្រូវការដែលទាក់ទងទៅនិងការរត់គេចខ្លួន ដំណើរផ្លាស់ប្តូរទីលំនៅទៅក្នុងប្រទេសថ្មីដែលមានភាសា និង វប្បធម៌ចំឡែក សង្គមរស់នៅ និងប្រព័ន្ធសង្គមនយោបាយខុសគ្នា។

ជំនួយឯកទេស និង អន្តរាគមន៍ឆាប់រហ័សជាភាពដ៏សំខាន់ដើម្បីទប់ទល់ចំពោះផលវិបាកនៃការជួបប្រទះទាំងនេះ ហើយនិងជួយចំពោះអ្នកដែលនៅរស់ពីទារុណកម្មនិងភ័យតក់ស្លុតទទួលបានមកវិញនូវលទ្ធភាពកសាងជីវិតដោយសំបូរសប្បាយ និង ពេញចិត្ត។

តាំងពីបានបើកទ្វារនៅចុងឆ្នាំ ១៩៨៨ មក STARTTS បានចេញមុខយ៉ាងសកម្មក្នុងការផ្តល់ជំនួយទាំងនោះ ហើយនិងបានបង្កើតការអភិវឌ្ឍន៍ថ្មីៗឆ្លើយតបទៅនិងសេចក្តីត្រូវការរបស់ជនភៀសខ្លួនដែលរស់នៅក្នុងរដ្ឋ NSW។

STARTTS តែងតាំងបុគ្គលិកដែលមានការពិសោធន៍និងយល់ដឹងយ៉ាងច្រើន មកពីសាវតារ និង វប្បធម៌ផ្សេងៗគ្នា ដែលបានបង្ហាញឲ្យឃើញអំពីក្រុមអតិថិជនរបស់យើង និង មានការផ្តល់ភាសារជាច្រើនផ្សេងៗគ្នាទៀតផង។

**បេសកកម្មរបស់ STARTTS** គឺ ដើម្បីអភិវឌ្ឍន៍ និង ប្រតិបត្តិមធ្យោបាយផ្សេងៗ ដើម្បីសំរួលដំណើរសះស្បើយសំរាប់អ្នកនៅរស់ពីទារុណកម្ម និង ការភ័យតក់ស្លុតនៃជនភៀសខ្លួន ហើយនិង ដើម្បីជួយនិងផ្តល់ជាមធ្យោបាយចំពោះ ម្នាក់ៗ និងអង្គការទាំងឡាយដែលធ្វើការជាមួយអ្នកនៅរស់ដើម្បីផ្តល់កិច្ចបំរើដោយសមរម្យ និង ដោយទទួលដឹងនូវវប្បធម៌ផ្សេងៗគ្នា។

**អតិថិជនរបស់យើង** ជាបុគ្គលម្នាក់ៗ និង សហគមន៍ទាំងឡាយដែលមកពីជនភៀសខ្លួន និង នៅក្នុងសភាពដូចជនភៀសខ្លួនហើយឥឡូវនេះរស់នៅក្នុងរដ្ឋ NSW និងនៅរស់ពីទារុណកម្ម និង ការជួបប្រទះការភ័យតក់ស្លុតផ្សេងៗទៀតនៅក្នុងសភាពដែលអំពើហោយោបានកើតមានឡើង។

**STARTTS** ផ្តល់ជូននូវកិច្ចបំរើគ្រប់បែបយ៉ាងដែលបានវិវឌ្ឍក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អតិថិជនដែលមានរាប់បញ្ចូល៖

- ★ ការពិភាក្សានិងប្តូរយោបល់ និង ព្យាបាល ដោយសមស្របតាមវប្បធម៌របស់អតិថិជន (សំរាប់មនុស្សម្នាក់ៗ, គ្រួសារ និង ក្រុមទាំងឡាយ)។
- ★ សរីរបរិហារ និង ជំនួយសំរាប់រាងកាយ ដោយមានរាប់បញ្ចូល ការជួបជាមួយម្នាក់ៗ, ការព្យាបាលការឈឺចាប់ជាក្រុម និង កម្មវិធីព្យាបាលនៅក្នុងទឹក។
- ★ សកម្មភាពសំរាប់យុវជន មានការបោះជំរំ, ដំណើរកំសាន្ត និងក្រុមជួបជុំ។
- ★ ជំនួយក្នុងការស្វែងរកការងារ និង ហ្វឹកហ្វឺន។
- ★ ធ្វើការបញ្ជូន និង រៀបចំសំណុំរឿង។
- ★ សម្ពន្ធការ និង ការពិគ្រោះជាមួយសហគមន៍។
- ★ គំរោងអភិវឌ្ឍន៍សហគមន៍។
- ★ ផ្តល់សិក្ខាកម្មចំពោះក្រសួងផ្សេងៗ នូវការយល់ដឹងអំពីបញ្ហាជន ភៀសខ្លួន និង រៀបចំដំណើរធ្វើការជាមួយអតិថិជនក្រុមនេះ។